# មេរៀនទី ១៥: កូនពៅខ្ជះខ្ជាយ

## លូកា ១៥:១១-៣២

**គោលបំណង៖** ព្រះអង្គជាព្រះនៃសេចក្តីស្រឡាញ់ និងការអត់ទោស។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១៤៥:៨** *"ព្រះយេហូវ៉ាទ្រង់ប្រកបដោយមេត្តាករុណានិងអាណិតអាសូរទ្រង់យឺតនឹងខ្ញាល់ ក៏មានសេចក្តីសប្បុរសដ៏ធំទូលាយ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

វាប្រហែលជាមិនមែនជារឿងចៃដន្យនោះទេ ដែលឪពុកមើលកូនប្រុសពីចម្ងាយស្គាល់បាន។ លើសពីនេះ នោះគឺគាត់កំពុងរង់ចាំមើលជារៀងរាល់ថ្ងៃថា កូនប្រុសរបស់គាត់នឹងត្រឡប់មកវិញ។ សូមសាកស្រមៃពីរូបភាពដែលព្រះទ្រង់អន្ទះសារចង់ជួបអ្នក បើទោះបីជាពេលអ្នកមានអារម្មណ៍អៀនខ្មាសក៏ដោយ។ នោះនឹងធ្វើឲ្យយើងបានស្គាល់ពីសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះអ្នក ហើយស្រឡាញ់ទំនាក់ទំនងដែលអ្នកមានជាមួយព្រះយេស៊ូវ។ អធិស្ឋានសម្រាប់កុមារណាដែលអាចនឹងត្រូវការជួបព្រះនៅថ្ងៃនេះ។

**ចំរៀង៖** ១. ព្រះយេស៊ូវស្រលាញ់កុមារណាស់ ២. ខ្ញុំដឹងខ្លួនហើយ ៣. ចូរបន្ទាបខ្លួននៅចំពោះ ព្រះអង្គ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត "អំពើបាប" "សេចក្តីស្រឡាញ់" និង "ការអត់ទោស"**

**សម្ភារៈដែលត្រូវការ៖** ក្រដាសដែលមានពាក្យថា "អំពើបាប" "សេចក្តីស្រឡាញ់" និង "ការអត់ទោស" នៅលើនោះ (សូមមើលទំព័រខាងក្រោម)

| |
|---|
| អំពើបាប |
| សេចក្តីស្រឡាញ់ |
| ការអត់ទោស |

១. សូមបត់ក្រដាសទាំងនោះ រួចចែកឲ្យទៅកុមារដែលមានទាំងពាក្យថា "អំពើបាប" "សេចក្តីស្រឡាញ់" និង "ការអត់ទោស"

២.ពេលដែលកុមារបានទទួលក្រដាសគ្រប់គ្នាហើយសុំឲ្យពួកគេបើកក្រដាសនោះមើល

៣. កុមារដែលកាន់ក្រដាសដែលមានពាក្យថា "អំពើបាប" ត្រូវស្វែងរកកុមារណាដែលកាន់ក្រដាស "សេចក្តីស្រឡាញ់" ឬ "ការអត់ទោស" (ពួកគេក៏អាចស្វែងរកអ្នកដែលមានពាក្យថា "សេចក្តីស្រឡាញ់" និង "ការអត់ទោស" ទាំងពីរក៏បាន)

៤.កុមារដែលកាន់ក្រដាសដែលមានពាក្យថា "សេចក្តីស្រឡាញ់" និង "ការអត់ទោស" ត្រូវស្វែងរកអ្នកណាដែលមានក្រដាសពាក្យថា "អំពើបាប"។

៥. ក្រុមណាដែលមានទាំង"អំពើបាប"+"ការអត់ទោស" ឬ "អំពើបាប"+"សេចក្តីស្រឡាញ់" ឬ "អំពើបាប" +"សេចក្តីស្រឡាញ់"+ "ការអត់ទោស" អាចអង្គុយចុះបាន។

៦.បើសិនកុមារៗណាដែលមានក្រដាសពាក្យថា "អំពើបាប" មិនអាចស្វែងរកអ្នកដែលមានពាក្យថា "សេចក្តីស្រលាញ់" និង "ការអត់ទោស" បានពួកគេអាចចូលអង្គុយជាមួយក្រុម "ក្តីស្រឡាញ់" ឬ "ការអត់ទោស" មួយ

ណាក៏បាន។
៧. សូមពន្យល់កុមារថាពេលដែលពួកគេធ្វើរឿងមិនល្អ នោះគេហៅថាជា“អំពើបាប” ហើយនៅពេលដែលយើងធ្វើបាប យើងនឹងចេញឆ្ងាយពីព្រះ។ មានផ្លូវតែមួយប៉ុណ្ណោះដែលអាចសំអាតយើងពីអំពើបាប គឺតាមរយៈសេចក្ដីស្រឡាញ់ និងការអត់ទោសរបស់ព្រះ។
៨. សូមឲ្យកុមារទាំងអស់និយាយថា “ព្រះស្រឡាញ់ខ្ញុំ ហើយទ្រង់អត់ទោសឲ្យខ្ញុំ” ។

## ៤. ការណែនាំមេរៀន

**សម្ភារៈដែលត្រូវការ៖** ចានដែកជ័រធំមានទឹក ប្រអប់ជ័រ ដុំថ្ម



១. ចាក់ទឹកចូលក្នុងចានដែកជ័រធំនោះ ហើយដាក់ឲ្យប្រអប់ជ័រអណ្ដែតលើទឹក
២. នៅពេលដែលយើងមានទំនាក់ទំនងល្អជាមួយព្រះ យើងប្រៀបដូចជាប្រអប់ជ័រដែលអណ្ដែតនៅលើទឹកអ៊ីចឹង។
៣. តែពេលដែលយើងប្រព្រឹត្តអំពើបាប យើងចាប់ផ្ដើមលិចចូលទៅក្នុងទឹក។



៤. តើយើងអាចធ្វើការអាក្រក់អ្វីខ្លះ? (ឧទាហរណ៍៖ កុហក ឈ្លោះគ្នា លួច ស្អប់គ្នា) ការអាក្រក់ទាំងអស់នេះជាអ្វីដែលយើងហៅថាអំពើបាប។
៥. ដាក់ថ្មចូលទៅក្នុងប្រអប់ជ័រនោះ ហើយឲ្យកុមាររៀបរាប់ពីអំពើបាបមួយចំនួនរហូតដល់ប្រអប់ជ័រលិចចូលទៅក្នុងទឹក។
៦. តែនៅពេលដែលយើងត្រឡប់ទៅរកព្រះវិញ ហើយទូលសូមការអត់ទោស ព្រះទ្រង់នឹងអត់ទោសឲ្យយើង
៧. សូមឲ្យកុមារនិយាយពាក្យ “សុំទោសព្រះអង្គ សូមអត់ទោសឲ្យកូនផង” បន្ទាប់មកយកដុំថ្មចេញពីប្រអប់ជ័រនៅគ្រប់ពេលដែលពួកគេនិយាយពាក្យនេះរហូតដល់ថ្មទាំងអស់ត្រូវបានយកចេញ ហើយប្រអប់ជ័រអណ្ដែតនៅលើទឹកវិញ។
៨. សូមចងចាំថាព្រះស្រឡាញ់យើង ហើយអត់ទោសឲ្យយើងពេលដែលយើងត្រឡប់មករកទ្រង់វិញ។
៩. សរុបមកវិញ តើអំពើបាបគឺជាអ្វីប្អូនៗ? អំពើបាបគឺជាការ គិតខុស និយាយខុស ធ្វើខុស ដែលព្រះទ្រង់មិនសព្វព្រះហឫទ័យ។ ឲ្យកុមារក្រោកឈរ ហើយធ្វើកាយវិកាយជាមួយគ្នា។

- គិតខុស៖ យកដៃមកចង្អុលក្បាលរបស់យើង។
- និយាយខុស៖ យកដៃមកចង្អុលមាត់ ។
- ធ្វើខុស៖ យើងក្ដាប់ដៃទាំងពីរហើយដំដៃលើគ្នាចុះឡើងៗ។
- ដែលព្រះទ្រង់មិនសព្វព្រះហឫទ័យ៖ យើងយកដៃទាំង២ធ្វើខ្វែងគ្នាចុះឡើង។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

មានឪពុកម្នាក់មានកូនប្រុស២នាក់។ ឪពុកមានលុយជាច្រើនឲ្យកូនប្រុសរបស់គាត់ ដើម្បីទុកជាមរតកមុនពេលដែលគាត់ស្លាប់។ ប៉ុន្តែកូនប្រុសពៅមិនចង់រង់ចាំទេ គាត់ក៏បាននិយាយថា “លោកឪពុកសូមឲ្យលុយមកខ្ញុំឥឡូវនេះមក”ឪពុកកើតទុក្ខជាខ្លាំងដែលឃើញកូនពៅរបស់គាត់មិនចេះរង់ចាំ ពីព្រោះការនេះបង្ហាញថាកូនពៅមិនបានស្រឡាញ់ឪពុកទេ។ ប៉ុន្តែឪពុកនៅតែឲ្យលុយនោះទៅគាត់។

កូនពៅបានចំណាយលុយទាំងអស់ទៅលើការសប្បាយរបស់គាត់។ គាត់បានចំណាយលុយទៅលើការជប់លៀង និងម្ហូបអាហារ ហើយចាយវាយជាមួយនឹងមិត្តភក្តិរបស់គាត់។ គ្រប់យ៉ាងដែលកូនពៅគិតគឺការសប្បាយភ្លើតភ្លើន។ កូនពៅមិនបានគិតពីឪពុក ឬពីក្តីស្រឡាញ់របស់ឪពុកចំពោះគាត់នោះទេ។ មិនយូរប៉ុន្មានកូនពៅក៏បានចាយលុយអស់។ គាត់មិនមានលុយសម្រាប់ទិញអាហារ ឬសំរាប់ចំណាយ ទៅលើផ្ទះដែលគាត់រស់នៅបានទេ។ កូនពៅមានការសោកស្តាយណាស់ ដែលគាត់បានខ្ជះខ្ជាយលុយដែលឪពុកឲ្យ។ គាត់ចង់ត្រឡប់ទៅផ្ទះវិញ ប៉ុន្តែគាត់ខ្លាចថាឪពុករបស់គាត់នឹងខឹងគាត់។ ដូច្នេះគាត់ក៏បានសំរេចចិត្តថា នឹងសុំឪពុករបស់គាត់ឲ្យទទួលយកគាត់ធ្វើជាអ្នកបំរើតែមិនមែនទទួលជាកូនទេ។

ប៉ុន្តែពេលដែលឪពុកឃើញគាត់ពីចំងាយ ឪពុកក៏រត់សំដៅទៅរកកូនពៅ។ ឪពុករងចាំកូនពៅត្រឡប់មកវិញរៀងរាល់ថ្ងៃ។ ឪពុកមិនបានខឹងនឹងកូនពៅទេ គាត់សប្បាយចិត្តណាស់ដែលឃើញកូនពៅត្រឡប់មករកគាត់វិញ! ឪពុកដឹងថាកូនពៅស្តាយនូវកំហុស ហើយដោយសារតែគាត់ស្រឡាញ់កូនឪពុកបានអត់ទោសឲ្យកូនពៅ។ ឪពុកបានឲ្យសំលៀកបំពាក់ថ្មីទៅកូនពៅ ហើយបានរៀបចំកម្មវិធីជប់លៀងយ៉ាងធំថែមទាំងអញ្ជើញមិត្តភក្តិរបស់គាត់ទាំងអស់មកចូលរួមទៀតផង។

នេះជាព្រះហឫទ័យដែលព្រះមានសំរាប់អ្នក និងខ្ញុំ។ នៅពេលដែលយើងធ្វើអ្វីខុស ហើយសុំការអត់ទោស ព្រះមិនចង់ឲ្យយើងលាក់បាំង ហើយរត់គេចពីព្រះអង្គនោះទេ។ ព្រះអង្គចង់ឲ្យយើងត្រឡប់ទៅរកទ្រង់វិញ ហើយទូលសុំការអត់ទោសពីទ្រង់។ ពេលដែលយើងធ្វើបែបនេះ ព្រះនឹងអត់ទោសឲ្យយើងព្រោះទ្រង់ស្រឡាញ់យើង។

**៦. សំនួរពិភាក្សា**

១. តើកូនប្រុសមួយណាដែលមិនចង់រងចាំ ហើយបានសុំឪពុកឲ្យចែកមរតកឲ្យ? *កូនពៅ*

២. តើការនេះបង្ហាញពីអ្វីនៅពេលដែលកូនពៅសុំឪពុកចែកមរតក?

*បានបង្ហាញថាកូនពៅរបស់គាត់មិនស្រឡាញ់ឪពុកខ្លួនទេ*

៣. តើកូនពៅយកលុយទៅចំណាយលើអ្វីខ្លះ?

*ផឹកស៊ី លេងល្បែងស៊ីសង ចូលក្លឹប សប្បាយជាមួយ មិត្តភក្តិ និងស្រាស្រី*

៤.តើឪពុកមានប្រតិកម្មដូចម្តេច នៅពេលដែលកូនប្រុសបានត្រឡប់មកផ្ទះវិញបន្ទាប់ពីបានចាយលុយអស់? *ឪពុកទទួលកូនដោយអោបថើប យកស្បែកជើងថ្មី អាវថ្មី ចិញ្ចៀន ស្រឡាញ់កូន និងអត់ទោសឲ្យកូន ហើយបានរៀបចំកម្មវិធីជប់លៀងយ៉ាងធំសំរាប់កូន*

៥.តើព្រះនឹងធ្វើអ្វីពេលដែលយើងត្រឡប់មករកព្រះវិញជាមួយនឹងចិត្តសោកស្តាយបន្ទាប់ពីបានធ្វើការអាក្រក់? *ព្រះនៅតែស្រឡាញ់ ហើយអត់ទោសឲ្យយើង*

**៧. ខគម្ពីរចងចាំ** ទំនុកដំកើង ១៤៥:៨

**៨. សកម្មភាព** សូមជួយកុមារៗឲ្យសរសេរខគម្ពីរចងចាំបន្ទាប់ពីពួកគេបានផាត់ពណ៌រួច

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

| |
|---|
| អំពើបាប |
| សេចក្តីស្រឡាញ់ |
| ការអត់ទោស |

# ព្រះយេស៊ូវស្រឡាញ់ខ្ញុំ និងអត់ទោសឲ្យខ្ញុំ



សូមសរសេរខគម្ពីរចងចាំ:______________________________

______________________________________________________

______________________________________________________

______________________________________________________